ថែទាំកុមារក្នុងគ្រួសារជាអាទិភាពចម្បង | REACT

# ការចូលរួមរបស់កុមារមានពិការភាព មានសារៈសំខាន់ !



ខែតុលា ឆ្នាំ២០២១


សហការគាំទ្រដោយ ៖

សហភាពអឺរ៉ុប

USAID ជំនួយពីពលរដ្ឋអាមេរិក

GHR FOUNDATION

Save the Children

unicef

ផលិតដោយ ៖

LIGHT FOR THE WORLD

## សេចក្តីបញ្ជាក់

ការបោះពុម្ពផ្សាយនេះអាចធ្វើទៅបានក្រោមជំនួយសប្បុរសធ៌មពីសហភាពអឺរ៉ុប ( EU ) និងទីភ្នាក់ងារជំនួយអាមេរិក ( USAID )។ ខ្លឹមសារនៃអត្ថបទទាំងមូល គឺជាការទទួលខុសត្រូវរបស់អង្គការ Light For The World ប្រចាំនៅប្រទេសកម្ពុជា ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ( EU ) ឬទីភ្នាក់ងារជំនួយអាមេរិក ( USAID ) នោះឡើយ។

## DISCLAIMER

This publication was made possible by the generous support of the European Union (EU) and the United States Agency for International Development (USAID). The contents are the responsibility of Light For The World Cambodia and do not reflect the views of the EU or USAID.



## ហេតុអ្វីការចូលរួមរបស់កុមារមានពិការភាព ក្នុងជីវិតគ្រួសារ និងសហគមន៍ មានសារៈសំខាន់ ?

អត្រាប្រេវ៉ាឡង់នៃកុមារមានពិការភាពនៅក្នុងប្រទេសកម្ពុជា ត្រូវបានប៉ាន់ប្រមាណថាមានចំនួន ១៥,៥ ភាគរយ។ កុមារទាំងនេះភាគច្រើនកំពុងរស់នៅក្នុងមណ្ឌលថែទាំ ដូចជាមណ្ឌលកុមារកំព្រា មណ្ឌលព្យាបាល និងមណ្ឌលការពារកុមារ។ ទោះជាយ៉ាងនេះក៏ដោយ កុមារអាចមានសុខភាពល្អប្រសើរច្រើន ប្រសិនបើរស់នៅជាមួយគ្រួសារបង្កើត ឬគ្រួសារធម៌ នៅក្នុងសហគមន៍របស់ខ្លួន។ ការចូលរួមរបស់កុមារមានពិការភាពនៅក្នុងជីវិតគ្រួសារ និងសហគមន៍ ជួយលើកកម្ពស់ការអភិវឌ្ឍរបស់កុមារ ព្រមទាំងជួយជំរុញឱ្យសង្គមប្រកបដោយបរិយាបន្នថែមទៀតផង។

## តើអ្វីជាកម្សោយ ហើយអ្វីជាពិការភាព ?

ពិការភាព និងកម្សោយ ជាញឹកញាប់ត្រូវបានប្រើជារបៀបដូចគ្នា។ ប៉ុន្តែតាមពិតវាមានអត្ថន័យខុសគ្នា៖

- **កម្សោយ** គឺជាការបាត់បង់មុខងារណាមួយរបស់រាងកាយ។
  ឧទាហរណ៍៖ នៅពេលនរណាម្នាក់មើលមិនឃើញច្បាស់។ កម្សោយ ភាគច្រើនមិនអាចព្យាបាលបានទេ ហើយអាចមានពេញមួយជីវិត។ ជួនកាល កម្សោយអាចត្រូវបានកែប្រែឱ្យប្រសើរឡើង ឧទាហរណ៍ ក្នុងករណីបញ្ហាខ្សោយគំហើញ គឺដោយការពាក់វ៉ែនតាជាជំនួយ។

- **ពិការភាព** គឺនៅពេលដែលបុគ្គលម្នាក់មានកម្សោយ ហើយជួបប្រទះនូវរបាំងក្នុងការអនុវត្ត ឬធ្វើសកម្មភាពអ្វីមួយ។
  ឧទាហរណ៍៖ ប្រសិនបើនរណាម្នាក់មានការពិបាកក្នុងការមើលដែលមិនអាចព្យាបាល និងមិនអាចអានអក្សរបាន។ ប្រសិនបើសម្ភារអំណានមានប្រើអក្សរស្ទាប(braille) នោះនឹងមិនមានរបាំងដែលរារាំងមិនឱ្យគាត់អានអក្សរនោះទេ។

**កម្សោយ + របាំង = ពិការភាព**

! ដូច្នេះ ៖ កម្សោយគឺមិនមែនជាបញ្ហានោះទេ ប៉ុន្តែរបាំងទៅវិញទេដែលធ្វើឱ្យជនដែលមានប្រភេទកម្សោយផ្សេងៗ មានការលំបាកក្នុងការចូលរួមធ្វើសកម្មភាពដូចអ្នកដទៃ។ ក្នុងករណីនោះ ពួកគាត់ត្រូវបានចាត់ទុកថាជាជនមានពិការភាព។

# ប្រភេទផ្សេងៗនៃកម្សោយ

កម្សោយមានច្រើនប្រភេទខុសៗគ្នា ហើយនៅពេលរួមផ្សំជាមួយនឹងរបាំង វាធ្វើឱ្យកុមារមានពិការភាព។ ការធ្វើចំណាត់ថ្នាក់នៃកម្សោយ មានភាពខុសគ្នាទៅតាមប្រទេសនីមួយៗ ប៉ុន្តែជាទូទៅ ចំណាត់ថ្នាក់ខាងក្រោមនេះត្រូវបានគេប្រើប្រាស់៖

- **ពិបាកក្នុងការផ្លាស់ទី** ៖ មានការពិបាកក្នុងការផ្លាស់ទី ការចាប់កាន់ ការស្ទាប ការធ្វើចលនា រាងកាយ និងសមត្ថភាពក្នុងការអនុវត្តសកម្មភាពរាងកាយ។
- **ពិបាកក្នុងការស្តាប់** ៖ បាត់បង់ការស្តាប់ក្នុងកម្រិតមួយ ដែលប្រែប្រួលចាប់ពីភាពថ្លង់ (ស្តាប់មិនឮសំឡេងសោះ) រហូតដល់ការបាត់បង់ការស្តាប់កម្រិតស្រាល(ពិបាកស្តាប់ឮសំឡេងតិចៗ)។
- **ពិបាកក្នុងការមើល** ៖ បាត់បង់គំហើញក្នុងកម្រិតមួយ ដែលប្រែប្រួលចាប់ពីគំហើញខ្សោយ រហូតដល់មើលមិនឃើញទាំងស្រុង។
- **ពិបាកក្នុងការនិយាយ** ៖ ពិបាកក្នុងការប្រាស្រ័យទាក់ទង ទាំងសមត្ថភាពក្នុងការនិយាយ និង/ឬការយល់ពីអ្នកដទៃវិញ។
- **ពិបាកក្នុងការរៀនសូត្រ** ៖ ការពិបាកពេញមួយជីវិតក្នុងការយល់ដឹង និងសមត្ថភាពផ្នែកបញ្ញារបស់មនុស្សម្នាក់ ដែលជាញឹកញាប់តម្រូវឱ្យមានការជួយត្រួតពិនិត្យលើការអនុវត្តសកម្មភាពប្រចាំថ្ងៃ។
- **ពិបាកផ្នែកសង្គម-ផ្លូវចិត្ត** ៖ ពិបាកក្នុងការយល់ដឹង មនោសញ្ចេតនា និង/ឬការគ្រប់គ្រងឥរិយាបថ។ ទាំងនេះរួមបញ្ចូលទាំងស្ថានភាពវេជ្ជសាស្រ្ត ដូចជាការថប់បារម្ភ ការធ្លាក់ទឹកចិត្ត ជំងឺវិកលចរិត និងជំងឺស្រ្តេសក្រោយការប៉ះទង្គិចផ្លូវចិត្ត។
- **មានកម្សោយច្រើនប្រភេទ** ៖ ការរួមបញ្ចូលគ្នានូវប្រភេទកម្សោយផ្សេងៗដែលបានរៀបរាប់ខាងលើ។

# ប្រភេទផ្សេងៗនៃរបាំង

កុមារមានពិការភាពអាចជួបប្រទះនូវរបាំងច្រើនប្រភេទ ដែលបង្អាក់ដល់ការចូលរួមរបស់ពួកគាត់នៅក្នុងជីវិតគ្រួសារ និងសហគមន៍។ ទោះបីជារបាំងជាក់លាក់ដែលកុមារមានពិការភាពបានជួបប្រទះ អាចមានភាពខុសប្លែកគ្នាក៏ដោយ ប៉ុន្តែចំណាត់ថ្នាក់ខាងក្រោមនេះអាចកំណត់នូវប្រភេទរបាំងសំខាន់ៗ៖

- **របាំងឥរិយាបថ** ៖ ឥរិយាបថអវិជ្ជមាន និងការវិនិច្ឆ័យមិនល្អទៅលើកុមារមានពិការភាព ឧ. ពីសំណាក់សមាជិកគ្រួសារ ឬសហគមន៍ ដែលបណ្តាលឱ្យមានភាពរើសអើង និងការធ្វើឱ្យអាម៉ាស់។ ជាញឹកញាប់ឥរិយាបថអវិជ្ជមានទាំងនេះ កើតឡើងដោយសារចំណេះដឹងអំពីពិការភាពនៅ មានកម្រិត។
- **របាំងការប្រាស្រ័យទាក់ទង** ៖ ព័ត៌មានសម្រាប់ជនដែលមានការពិបាកក្នុងការមើល ស្តាប់ ឬប្រាស្រ័យទាក់ទង គឺមិនមានផ្តល់ជាទម្រង់មួយដែលពួកគាត់អាចប្រើប្រាស់បាន ឧទាហរណ៍ ប្រសិនបើសម្ភារសាលាមិនមានជាអក្សរស្ទាប(braille) ឬនៅពេលដែលគ្មានគ្រូដែលចេះភាសាសញ្ញា។
- **របាំងការបង្កលក្ខណៈងាយស្រួល** ៖ នេះអាចរួមបញ្ចូលទាំងរបាំងរូបវ័ន្តនៅក្នុងសហគមន៍ ដូចជាជណ្តើរដែលគ្មានជម្រាល ដូច្នេះកុមារមានពិការភាព មានការពិបាកក្នុងការផ្លាស់ទី។
- **របាំងស្ថាប័ន ឬនីតិប្បញ្ញត្តិ** ៖ ទាំងនេះរួមមានច្បាប់ គោលនយោបាយ យុទ្ធសាស្រ្ត ឬការអនុវត្តនានាដែលរើសអើងកុមារមានពិការភាព។ របាំងបែបនេះច្រើនតែភ្ជាប់ទៅនឹងបទដ្ឋានសង្គម និងវប្បធម៌ ហើយត្រូវបានបញ្ចូលទៅក្នុងគោលនយោបាយ និងច្បាប់។

# តើការចូលរួមមានន័យដូចម្តេច ?

ការចូលរួមមានន័យថា៖

- កុមារមានពិការភាព **មានលទ្ធភាពចូលរួមប្រកបដោយអត្ថន័យ**ក្នុងសកម្មភាពសង្គម វប្បធម៌ អប់រំ និងសកម្មភាពផ្សេងៗទៀត ដោយមិនមានការរើសអើងលើប្រភេទកម្សោយរបស់ពួកគេ ឬដោយបរិយាកាសមិនអំណោយផល ដូចជាឥរិយាបថអវិជ្ជមាន ឬឧបសគ្គរូបវន្ត នោះទេ។

- កុមារមានពិការភាព អាច**ពិភាក្សា និងសហការរៀបចំយ៉ាងស្មើភាពគ្នា**ក្នុងសកម្មភាពទាំងឡាយដែលពួកគាត់ចង់ចូលរួម។ នេះមានន័យថា ពួកគាត់មានឱកាសចែករំលែកមតិរបស់ខ្លួន ហើយអ្នកដទៃស្តាប់គំនិតរបស់គាត់ និងយកមកពិចារណា។



## ក្របខណ្ឌ និងបទប្បញ្ញត្តិច្បាប់ជាតិ និងអន្តរជាតិដែលគាំទ្រសិទ្ធិរបស់កុមារក្នុងការចូលរួម

- **គោលនយោបាយកម្ពុជា ឆ្នាំ២០០៦ ស្តីពីការថែទាំជំនួសសម្រាប់កុមារ**
  គោលនយោបាយនេះកត់សម្គាល់ថា ការថែទាំតាមគ្រួសារ និងតាមសហគមន៍ គឺជាជម្រើសដ៏ប្រសើរបំផុត ដើម្បីការអភិវឌ្ឍវិជ្ជមានសម្រាប់កុមារមានពិការភាព។

- **ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ**
  ច្បាប់កម្ពុជាទទួលស្គាល់នូវសិទ្ធិរបស់កុមារមានពិការភាព ក្នុងការចូលរួមក្នុងសកម្មភាពសង្គម វប្បធម៌ អប់រំ និងសកម្មភាពផ្សេងៗទៀត។ មាត្រា ១៨ ចែងថា ស្ថាប័ននានាត្រូវជួយសម្រួលដល់ការចូលរួម "នៅក្នុងផែនការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងវប្បធម៌ ដែលអាចប៉ះពាល់ដល់ផលប្រយោជន៍របស់ជនមានពិការភាព" ។

- **អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ**
  មាត្រា ១៩ ទទួលស្គាល់ថាជនមានពិការភាព មានសិទ្ធិពេញលេញក្នុងការរាប់បញ្ចូល និងចូលរួមក្នុងសហគមន៍ដោយមានការសម្រេចចិត្តស្មើនឹងអ្នកដទៃដែរ។ ហើយគួរមានការធានាថា កុមារមានពិការភាពមានសិទ្ធិក្នុងការបញ្ចេញមតិដោយសេរីលើគ្រប់បញ្ហាទាំងឡាយដែលប៉ះពាល់ដល់ពួកគាត់ ដូចមានចែងក្នុងមាត្រា ៧ ។

- **អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (១៩៨៩)**
  អនុសញ្ញានេះទទួលស្គាល់ថា គ្រួសារគឺជា "មូលដ្ឋានគ្រឹះរបស់សង្គម និងបរិយាកាសធម្មជាតិ ដើម្បីការលូតលាស់ និងសុខុមាលភាពរបស់សមាជិកទាំងអស់ ជាពិសេសគឺកុមារ" រួមទាំងកុមារមានពិការភាពផងដែរ។ មាត្រា ២៣ បានសង្កត់ធ្ងន់ថា កុមារមានពិការភាពគួរទទួលបានជីវិតពេញលេញ និងសមរម្យ ក្នុងស្ថានភាពដែលលើកកម្ពស់ការជឿជាក់លើខ្លួនឯង និងជួយសម្រួលដល់ការចូលរួមយ៉ាងសកម្មរបស់កុមារនៅក្នុងសហគមន៍។

- **គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព**
  ការចូលរួមក្នុងជីវិតគ្រួសារ និងសហគមន៍ដោយកុមារមានពិការភាព គឺជាមូលដ្ឋានគ្រឹះដើម្បីសម្រេចបាននូវសុខភាព និងសុខុមាលភាពជាសកល ដែលមានចែងក្នុងគោលដៅទី៣ ។ ឱកាសសម្រាប់ការរៀនសូត្រពេញមួយជីវិតតាមរយៈការអប់រំប្រកបដោយបរិយាបន្ន ត្រូវបានលើកឡើងនៅក្នុងគោលដៅទី៤ និងសង្កត់ធ្ងន់លើសារៈសំខាន់នៃការចូលរួមរបស់កុមារមានពិការភាព។

# ហេតុអ្វីការចូលរួមរបស់កុមារមានពិការភាពមានសារៈសំខាន់ ?

កុមារទាំងអស់ រួមទាំងកុមារមានពិការភាព មានសិទ្ធិចូលរួមក្នុងជីវិតគ្រួសារ និងសហគមន៍។ លើសពីនេះទៀត វាមានសារៈសំខាន់សម្រាប់សុខភាព សុខុមាលភាព និងការអភិវឌ្ឍខ្លួនរបស់កុមារមានពិការភាព ដើម្បីចូលរួមសកម្មភាពនៅផ្ទះ សាលារៀន និងសហគមន៍។ បន្ថែមលើនេះ ក្រុមគ្រួសាររបស់ពួកគាត់ ក៏ដូចជាសមាជិកសហគមន៍ នឹងទទួលបានអត្ថប្រយោជន៍ពីការវិនិយោគលើការចូលរួមរបស់កុមារមានពិការភាពផងដែរ។ ផ្នែកខាងក្រោមនេះ ផ្តល់ការសង្ខេបអំពីថា តើការចូលរួមរបស់កុមារមានពិការភាព អាចផ្តល់អត្ថប្រយោជន៍ដល់មនុស្សគ្រប់គ្នា ដោយរបៀបណា។

## អត្ថប្រយោជន៍នៃការចូលរួម របស់កុមារមានពិការភាព

ការចូលរួមរបស់កុមារមានពិការភាពក្នុងជីវិតគ្រួសារ និងសហគមន៍ ធ្វើឱ្យប្រសើរឡើងដើម្បីការអភិវឌ្ឍវិជ្ជមាន ពីព្រោះវា ៖

- ជំរុញការបង្កើតមិត្តភាព និងអារម្មណ៍យល់ថាពួកគេស្ថិតក្នុងក្រុមតែមួយ។
- ផ្តល់ឱកាសដើម្បីរៀនសូត្រ និងប្រាស្រ័យទាក់ទងជាមួយមិត្តភក្តិដែលគ្មានពិការភាព។
- ជួយឱ្យកុមារស្វែងយល់ និងស្គាល់ពីជីវិតជាសមាជិករបស់សហគមន៍។
- បង្កើនជំនាញប្រាស្រ័យទាក់ទងរបស់ពួកគាត់ និងបង្កើនទំនុកចិត្តលើខ្លួនឯង។
- បង្កើតឱកាសកាន់តែប្រសើរ ដើម្បីដឹកនាំជីវិតឯករាជ្យនៅពេលអនាគត។

## អត្ថប្រយោជន៍នៃការចូលរួមរបស់កុមារមានពិការភាព សម្រាប់សមាជិកគ្រួសារ

ការជំរុញការចូលរួមរបស់កុមារមានពិការភាពនៅក្នុងគ្រួសារនឹង ៖

- ជួយឱ្យកុមារអភិវឌ្ឍបំនិនជីវិត ដូចជាធ្វើម្ហូប ថែសួន និងការសម្អាត។
- បង្កើនសមត្ថភាពរបស់ពួកគាត់ក្នុងការថែទាំខ្លួនឯង និងអ្នកដទៃ។
- ជួយសម្រាលបន្ទុកថែទាំរបស់គ្រួសារ ដោយសារកុមារកាន់តែមានភាពឯករាជ្យ។
- បង្កើនក្តីសង្ឃឹមផ្នែកសេដ្ឋកិច្ចរបស់គ្រួសារ ប្រសិនបើកុមារមានពិការភាពបានទៅសាលារៀន។
- បង្កើនវត្តមានរបស់កុមារមានពិការភាព ដែលរួមចំណែកដល់ការយល់ដឹង និងទទួលយកកាន់តែច្រើនដោយបរិស្ថានជុំវិញ។

## អត្ថប្រយោជន៍នៃការចូលរួមរបស់កុមារមានពិការភាព សម្រាប់សហគមន៍ទាំងមូល

ប្រសិនបើកុមារមានពិការភាព ទទួលបានឱកាសចូលរួមក្នុងជីវិតសហគមន៍ នោះវានឹង ៖

- ជួយពង្រឹងវប្បធម៌ដែលសហគមន៍តែងតែជួយគាំទ្រកុមារងាយរងគ្រោះ។
- ផ្តល់ឱកាសដល់កុមារក្នុងការរួមចំណែកការអភិវឌ្ឍសហគមន៍។
- ជួយជំរុញឱ្យមានសង្គមមួយប្រកបដោយបរិយាបន្ន និងសមធម៌ ដែលផ្តល់ផលប្រយោជន៍ដល់សមាជិកទាំងអស់គ្នា។
- បង្កើនឱកាសអតិបរមាសម្រាប់សហគមន៍ឱ្យមានសុខភាពល្អ សុភមង្គល និងផលិតភាព។

# តើធ្វើដូចម្ដេច ដើម្បីបង្កើនការចូលរួមរបស់កុមារមានពិការភាព?

របាំងឥរិយាបថ ការប្រាស្រ័យទាក់ទង ការបង្កលក្ខណៈងាយស្រួល និងរបាំងស្ថាប័ន ដែលកុមារមានពិការភាព អាចជួបប្រទះ អាចត្រូវបានដោះស្រាយដោយដំណោះស្រាយសាមញ្ញៗ។ តារាងខាងក្រោមនេះផ្ដល់នូវទិដ្ឋភាពទូទៅនៃបញ្ហាប្រឈម និងណែនាំនូវកិច្ចអន្តរាគមន៍ជាក់ស្ដែងសម្រាប់បុគ្គលិកសង្គម ដើម្បីជំរុញការចូលរួមរបស់កុមារមានពិការភាព។

**របាំង ៖ ឥរិយាបថអវិជ្ជមាន និងបញ្ហាប្រឈមនៃការប្រាស្រ័យទាក់ទងរបស់កុមារ**

| បញ្ហាប្រឈម | ដំណោះស្រាយ | សកម្មភាព |
|---|---|---|
| ការថប់បារម្ភផ្នែកសង្គម ឬកង្វះភាពជឿជាក់លើខ្លួនឯងរបស់កុមារមានពិការភាព ធ្វើឱ្យពួកគាត់ស្ទាក់ស្ទើរក្នុងការចូលរួម។ | ធ្វើការជាមួយអាណាព្យាបាល ដោយលើកទឹកចិត្តកុមារមានពិការភាពតាំងពីវ័យក្មេង ឱ្យមានតួនាទីសំខាន់នៅក្នុងគ្រួសារ និងលើសពីនេះ ស្របតាមសមត្ថភាពលូតលាស់របស់គាត់។ | • លើកទឹកចិត្តអាណាព្យាបាលឱ្យយកកុមារទៅជាមួយ តាំងពីនៅក្មេង នៅពេលចេញធ្វើការងារផ្សេងៗនៅក្រៅផ្ទះ។<br>• ជំរុញអាណាព្យាបាលឱ្យប្រាស្រ័យទាក់ទងជាមួយកុមារ អំពីអារម្មណ៍របស់ពួកគាត់។ ការប្រើប្រាស់ក្ដារខៀនប្រាស្រ័យទាក់ទង ដែលមានរូបភាព/គំនូសដែលតំណាងឱ្យអារម្មណ៍ផ្សេងៗ អាចជាឧបករណ៍ដ៏មានប្រយោជន៍។<br>• លើកទឹកចិត្តអាណាព្យាបាលឱ្យបង្ហាញក្ដីស្រឡាញ់របស់ខ្លួន និងប្រាប់កូនថាគាត់ស្រឡាញ់កូន។ ឱ្យពួកគាត់សរសើរកុមារចំពោះការខិតខំប្រឹងប្រែង និងរាល់សមិទ្ធផលរបស់កុមារ។<br>• ប្រើរឿងនិទាន ដើម្បីពន្យល់កុមារថាការថប់បារម្ភ គឺជារឿងធម្មតា រួចផ្ដល់ឧទាហរណ៍អំពីវិធីជម្នះលើវា។ ការនិយាយពីជនគំរូ អាចមានសារប្រយោជន៍ផងដែរ។<br>• លើកទឹកចិត្តកុមារឱ្យចាប់យកផ្នត់គំនិតលូតលាស់ ហើយហ៊ាននិយាយដោយខ្លួនឯង និងសុំការគាំទ្រ។ |
| កុមារដែលមានការពិបាកក្នុងការស្ដាប់ មិនចូលរួមដោយសារឧបសគ្គការប្រាស្រ័យទាក់ទង។ | ធ្វើការរួមគ្នាជាមួយអាណាព្យាបាល អំពីជំនាញយល់ដឹងរបស់កុមារ និងការអភិវឌ្ឍភាសាសញ្ញា។ | • ណែនាំនិងផ្សារភ្ជាប់អាណាព្យាបាលឱ្យស្គាល់អ្នកប្រើភាសាសញ្ញាដែលស្ទាត់ជំនាញ និងសហគមន៍មនុស្សថ្លង់។<br>• ផ្ដល់ជូនអាណាព្យាបាលនូវឧបករណ៍ដែលជួយអភិវឌ្ឍភាសាសញ្ញា ឧទាហរណ៍ វចនានុក្រមភាសាសញ្ញា។<br>• ធ្វើការជាមួយអាណាព្យាបាល ដើម្បីអភិវឌ្ឍវិធីសាស្ត្រប្រាស្រ័យទាក់ទង និងរៀនពីភាសាសញ្ញា។ |

## របាំង ៖ឥរិយាបថអវិជ្ជមាន និងចំណេះដឹងមានកម្រិតរបស់ អាណាព្យាបាល

| បញ្ហាប្រឈម | ដំណោះស្រាយ | សកម្មភាព |
| --- | --- | --- |
| កុមារមានពិការភាព និងអាណាព្យាបាលរបស់គាត់ មិនមានការយល់ដឹងពីសិទ្ធិរបស់កុមារមានពិការភាពក្នុងការចូលរួម និងពីគុណតម្លៃនៃការចូលរួមរបស់កុមារ។ | ធ្វើឱ្យកុមារមានពិការភាព ក៏ដូចជាអាណាព្យាបាលយល់ដឹងថាវាជាសិទ្ធិរបស់ពួកគាត់ក្នុងការចូលរួម និងគុណតម្លៃបន្ថែមនៅពេលត្រូវបានគេរាប់បញ្ចូល។ | • ពន្យល់កុមារ និងអាណាព្យាបាលអំពីសារៈសំខាន់នៃការចូលរួម (ឧទាហរណ៍ ដោយប្រើមូលហេតុនៃការចូលរួមដែលបានបង្ហាញខាងលើ)។<br>• ជំរុញភាពជឿជាក់ និងបំបាត់ការរើសអើងខ្លួនឯង ដោយការចែករំលែក (ឧទាហរណ៍ តាមរយៈវីដេអូ ឬរូបភាព) សាច់រឿងជោគជ័យរបស់កុមារមានពិការភាពដទៃទៀត ដោយបង្ហាញនូវអ្វីដែលពួកគេអាចធ្វើបាន ទោះបីជាមានការពិបាកក៏ដោយ។<br>• ពន្យល់អាណាព្យាបាលថា កុមារមានពិការភាពមានសិទ្ធិចូលរួមសកម្មភាពក្នុងគ្រួសារ ក្នុងសហគមន៍ និងនៅសាលារៀន។<br>• យោងទៅអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ (UNCRC) និងអនុសញ្ញាស្ដីពីសិទ្ធិជនពិការ (CRPD) ដែលបានពន្យល់នៅក្នុងឯកសារនេះ។<br>• ធ្វើឱ្យពួកគាត់យល់ពីគុណតម្លៃនៃការចូលរួម ដោយការរៀបចំសកម្មភាព ដូចជាលេងហ្គេមជាមួយគ្នា បោះបាល់ឱ្យគ្នា។ |
| អាណាព្យាបាលមិនផ្ដល់ឱកាសសម្រាប់ការចូលរួមទេ ព្រោះពួកគាត់គិតថាកុមារមានពិការភាព មិនអាចចូលរួមសកម្មភាពបាន។ | ស្វែងយល់រួមគ្នាជាមួយកុមារមានពិការភាពនិងអាណាព្យាបាល នូវអ្វីដែលពួកគាត់អាចធ្វើបានដោយឯករាជ្យផ្នែករាងកាយ និងសង្គម និងអ្វីដែលត្រូវការជំនួយខ្លះ។ | • ទៅជួបកុមារនៅផ្ទះ នៅពេលដែលអាណាព្យាបាលកំពុងមានវត្តមាន។ ឱ្យកុមារពន្យល់ និងបង្ហាញពីអ្វីដែលគាត់តែងតែធ្វើក្នុងមួយថ្ងៃៗ។ ស្ដាប់សាច់រឿងរបស់គាត់ និងសង្កេតមើលសកម្មភាពដែលកុមារអាចធ្វើបានដោយខ្លួនឯង (ឧទាហរណ៍ ស្លៀកពាក់ដោយខ្លួនឯង លេងជាមួយបងប្អូន)។ ផ្ដល់យោបល់ត្រឡប់ឱ្យអាណាព្យាបាលដើម្បីបញ្ជាក់ពីអ្វីដែលកុមារអាចធ្វើបានដោយឯករាជ្យ។ សួរថាតើសកម្មភាពអ្វីផ្សេងទៀតដែលកុមារចង់ធ្វើ និងថាតើគាត់ត្រូវការការគាំទ្រដូចម្ដេចខ្លះដើម្បីធ្វើកិច្ចការនេះ។<br>• សុំឱ្យកុមារដែលមាន និងគ្មានពិការភាពប្រាប់ឧទាហរណ៍អំពីហ្គេមដែលពួកគេលេងជាមួយគ្នា ហើយសួរពួកគេថាតើមានអារម្មណ៍បែបណាចំពោះការលេងជាមួយគ្នានេះ។<br>• សង្កត់ធ្ងន់ថាកុមារអាចជួយគ្នាទៅវិញទៅមក ដើម្បីធានាថាអ្នកគ្រប់គ្នាអាចចូលរួមលេងហ្គេមបាន។ |

| | | |
|---|---|---|
| អាណាព្យាបាលមិនគាំទ្រការចូលរួមទេ ព្រោះពួកគាត់មិនដឹងពីរបៀបជំរុញការចូលរួមរបស់កុមារមានពិការភាព។ | ផ្តល់ជូនអាណាព្យាបាលនូវចំណេះដឹង ឧបករណ៍ និងជំនាញផ្សេងៗ ដើម្បីលើកកម្ពស់ និងគាំទ្រដល់ការចូលរួម។ ម៉្យាងទៀត សូមសួរដំបូន្មានពីកុមារផ្ទាល់ពីរបៀបធ្វើកិច្ចការនេះ។ | • ចាប់ផ្តើមការសន្ទនាជាមួយអាណាព្យាបាល រួចស្វែងយល់ថាតើពួកគាត់ប្រឈមនឹងការលំបាកអ្វីខ្លះ។<br>• បង្ហាញឧទាហរណ៍នៃការចូលរួម ដោយប្រើរូបភាព វីដេអូខ្លីៗ ។ល។<br>• រៀបចំវគ្គសិក្សារួមគ្នា ដែលក្នុងពេលនោះអាណាព្យាបាលទាំងឡាយអាចផ្លាស់ប្តូរបទពិសោធន៍របស់ខ្លួនអំពីការគាំទ្រកូនៗក្នុងការចូលរួម។<br>• ពិភាក្សាជាមួយបុគ្គលិកសហគមន៍ផ្សេងទៀត ថាតើពួកគាត់ជំរុញការចូលរួមរបស់កុមារយ៉ាងដូចម្តេច និង/ឬសួរអាណាព្យាបាលពីឧទាហរណ៍ល្អខ្លះៗអំពីការគាំទ្រកូនរបស់គាត់។ |

| **របាំង ៖ ការមិនបង្កលក្ខណៈងាយស្រួល និងឥរិយាបថអវិជ្ជមាននៅក្នុងសហគមន៍** | | |
|---|---|---|
| **បញ្ហាប្រឈម** | **ដំណោះស្រាយ** | **សកម្មភាព** |
| ការចូលរួមរបស់កុមារមានពិការភាពក្នុងសកម្មភាពសង្គម អប់រំ ឬសេដ្ឋកិច្ច នៅមានកម្រិតដោយសារកង្វះការបង្កលក្ខណៈងាយស្រួលនៅទីតាំងទាំងនោះ។ | ធ្វើការជាមួយកុមារមានពិការភាពនិងអាណាព្យាបាលជ្រើសរើសទីតាំងដែលអាចចូលទៅយ៉ាងងាយបំផុត និងមានការបង្កលក្ខណៈងាយស្រួលយ៉ាងពេញលេញ។ ពិភាក្សាថាតើគួរមានការកែសម្រួលអ្វីខ្លះដែលអាចបង្កើនភាពងាយស្រួលសម្រាប់កុមារ។ | • ធ្វើការជាមួយកុមារ និងអាណាព្យាបាល ទៅពិនិត្យមើលទីតាំងដែលមានសកម្មភាពជាក់លាក់កើតឡើង (ឧទាហរណ៍ អគារសាលារៀន) ដើម្បីកំណត់ឧបសគ្គដែលរារាំងកុមារក្នុងការចូលរួម (ឧទាហរណ៍ ថ្នាក់រៀនស្ថិតនៅជាន់ទី១) រួចពិភាក្សាពីដំណោះស្រាយដែលអាចធ្វើបាន (ឧទាហរណ៍ ផ្លាស់ប្តូរពីថ្នាក់រៀនពីជាន់ទី១ មកជាន់ផ្ទាល់ដី ឬសាងសង់ជម្រាលផ្លូវឡើងទៅជាន់ទី១)។<br>• បន្ទាប់ពីបានអនុវត្តការកែសម្រួលដើម្បីកែលម្អការបង្កលក្ខណៈងាយស្រួលរបស់ទីតាំងនោះរួចមក ចូរពិនិត្យជាមួយកុមារ ថាតើវាបានបង្កើនការចូលរួមរបស់គាត់ដែរឬទេ។ |
| កង្វះមធ្យោបាយធ្វើដំណើរ និង/ឬការចំណាយពាក់ព័ន្ធដែលបង្អាក់ការចូលរួមរបស់កុមារមានពិការភាព។ | ស្វែងរកឱកាសសម្របសម្រួលការធ្វើដំណើរ ឬឱកាសសម្រាប់សកម្មភាពនៅផ្ទះ។ | • ផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ការធ្វើដំណើរ ឬស្វែងរកសេវាដឹកជញ្ជូនសមរម្យ។ ពិភាក្សាបញ្ហានេះជាមួយអាជ្ញាធរមូលដ្ឋាន និងសុំដំបូន្មានពីក្រុមគាំទ្រឪពុកម្តាយនៃជនមានពិការភាព។<br>• ឱ្យអ្នកផ្សេងមកជួបកុមារមានពិការភាព ជាជាងឱ្យគាត់ទៅជួបគេ។<br>• ផ្តល់សេវាគាំទ្រតាមផ្ទះនៅពេលដែលអាច និងចង់បាន។ |

| | | |
|---|---|---|
| | | • ពន្យល់អ្នកផ្តល់សេវាដឹកជញ្ជូនថា មធ្យោបាយដឹកជញ្ជូនដែលគ្មានលក្ខណៈងាយស្រួល គឺជារបាំងចំពោះកុមារមានពិការភាពក្នុងការចូលរួម រួចគាំទ្រពួកគាត់ក្នុងការកែលម្អការបង្កលក្ខណៈងាយស្រួល។ |
| ឥរិយាបថអវិជ្ជមានរបស់សហគមន៍ចំពោះ អាណាព្យាបាល និង/ឬ កុមារមានពិការភាព ធ្វើឱ្យ អាណាព្យាបាលស្ទាក់ស្ទើរ មិនហ៊ានបើកចំហរអំពីពិការភាពរបស់កូនគាត់។ | ធ្វើការរួមគ្នាជាមួយអ្នកដឹកនាំសហគមន៍ និងអាណាព្យាបាល ដើម្បីការទទួលយករបស់សង្គម ដោយការលុបបំបាត់ជំនឿមិនពិត តាមរយៈការប្រើព័ត៌មានពិត និងភស្តុតាង។ | • ណែនាំ និងផ្សារភ្ជាប់អាណាព្យាបាលឱ្យស្គាល់ឪពុកម្តាយដទៃទៀតរបស់កុមារមានពិការភាពដែលបានជម្នះឧបសគ្គដូចគ្នានេះ។<br>• លើកទឹកចិត្តអាណាព្យាបាលឱ្យចែករំលែករឿងរ៉ាវរបស់ខ្លួន ជាមួយសមាជិកដទៃទៀតក្នុងសហគមន៍។<br>• ប្រើប្រាស់ឧទាហរណ៍នៃជនគំរូក្នុងប្រទេស និងក្នុងពិភពលោក។ |

## របាំង ៖ កង្វះមូលដ្ឋានគ្រឹះ
## ស្ថាប័ន ឬនីតិប្បញ្ញត្តិ

| បញ្ហាប្រឈម | ដំណោះស្រាយ | សកម្មភាព |
|---|---|---|
| ការចូលរួមរបស់កុមារមានពិការភាពក្នុងសកម្មភាពអប់រំត្រូវបានរាំងស្ទះ ដោយសាររបាំងផ្នែកស្ថាប័ន។ | ធ្វើការរួមគ្នាជាមួយសមាគមន៍ឪពុកម្តាយ-គ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលា ដើម្បីកែលម្អការដាក់បញ្ចូលកុមារមានពិការភាពនៅក្នុងសាលារៀន។ | • សម្របសម្រួលការបញ្ចូលកុមារទៅក្នុងសាលារៀនដោយប្រើក្របខ័ណ្ឌច្បាប់ និងអាជ្ញាធរ។<br>• ធានាថាកុមារមានពិការភាពមានវត្តមាន(ឬត្រូវបានមើលឃើញ) នៅក្នុងយុទ្ធនាការចុះឈ្មោះចូលរៀនរបស់រដ្ឋ។<br>• ផ្តល់ជូនគ្រូបង្រៀន/នាយកសាលា នូវចំណេះ និងការយល់ដឹងអំពីបរិយាបន្នពិការភាព និងវិធីសាស្រ្តបង្រៀនប្រកបដោយបរិយាបន្ន។ |
| មានការខ្វះខាតឧបករណ៍ជំនួយ ការផ្លាស់ទី និងសម្ភារសិក្សាដែលអាចកែសម្រួលបាន ដែលធ្វើឱ្យបង្អាក់ដល់ការចូលរួម។ | ស្វែងរកការគាំទ្រពីរដ្ឋាភិបាល និងអង្គការអន្តរជាតិមិនមែនរដ្ឋាភិបាលផ្សេងទៀត ដើម្បីផ្តល់ការគាំទ្រឱ្យកាន់តែប្រសើរ។ | • លើកទឹកចិត្តដល់អង្គការអន្តរជាតិក្រៅរដ្ឋាភិបាល និងមន្រ្តីទទួលបន្ទុកមុខងាររបស់រដ្ឋាភិបាលក្នុងការផ្តល់ការគាំទ្រ។<br>• លើកកម្ពស់ការយល់ដឹងអំពីការប្រើប្រាស់ លទ្ធភាពនៃការប្រើប្រាស់ និងអត្ថប្រយោជន៍នៃឧបករណ៍ជំនួយ និងសម្ភារដែលត្រូវបានកែសម្រួល។<br>• ស្វែងរកក្រុមហ៊ុន/អង្គការដែលអាចផលិតឧបករណ៍ជំនួយ ដោយប្រើសម្ភារក្នុងស្រុក និងមានតម្លៃសមរម្យ។ |




**Light For The World ប្រចាំប្រទេសកម្ពុជា**
អាសយដ្ឋាន៖ មីលីនីមថៅវើរ (ជាន់ទី១) អគាលេខ ៦៨ ផ្លូវលេខ ៥៧
សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ

ហ្វេសប៊ុគផេក៖ Light for the World- Cambodia

អ៊ីម៉ែល៖ David Curtis: d.curtis@light-for-the-world.org
Virak Kheng: v.kheng@light-for-the-world.org

LIGHT FOR THE WORLD